# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃសុក្រ ២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម៖**

១- ប្រធានអង្គប្រជុំ ឯកឧត្តមបណ្ឌិត **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធដែលចូលរួមផ្ទាល់ចំនួន២២រូប និងតាមប្រព័ន្ធអនឡាញចំនួន៤១រូប សរុបចំនួន៦៣រូប។

**៤. របៀបវារៈ៖**

១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ ឯកឧត្តមបណ្ឌិត **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

២-បទបង្ហាញស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀន បង្ហាញដោយ ឧត្តមសេនីយ៍ឯក **លឹម តុងហួត** ប្រធាននាយកដ្ឋានផ្សព្វផ្សាយ អប់រំ និងទំនាក់ទំនងសាធារណៈ។

៣- មតិបូកសរុប និងបិទកម្មវិធីដោយ ឯកឧត្តមបណ្ឌិត **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល៖**

ជាកិច្ចចាប់ផ្តើម ឯកឧត្តមបណ្ឌិត **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេសបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯកឧត្តមបណ្ឌិត បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសមាជិកសមាជិកានៃកិច្ចប្រជុំហើយឯកឧត្តមបានបញ្ជាក់ថា រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមកិច្ចដឹកនាំប្រកប

ដោយគតិបណ្ឌិតឈ្លាសវៃ និងស្នាហាប់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបន្តចាត់ទុកការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ជាការងារអាទិភាពដែលបានបញ្ចូលក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន។

ឧត្តមសេនីយ៍ឯក **លឹម តុងហួត** ប្រធាននាយកដ្ឋានផ្សព្វផ្សាយ អប់រំ និងទំនាក់ទំនងសាធារណៈ មានប្រសាសន៍នៅក្នុងឱកាសដែលលោកទទួលបានការអនុញ្ញាតពីឯកឧត្តម នាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែកុម្ភៈស្តីពី «ការឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀន»។ ឧត្តមសេនីយ៍ឯក **លឹម តុងហួត** បានបញ្ជាក់ថា បន្ទាប់មានការឆ្លងរាលដាលជំងឺអេដស៍ចូលដល់កម្ពុជា ហើយរកឃើញថា អ្នកប្រើគ្រឿងញៀនដោយចាក់ អាចនាំឱ្យមានការឆ្លងរាលដាលជំងឺអេដស៍។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានទទួលយកការស្នើសុំពីដៃគូ ពិសេស UNODC, WHO និង UNAIDS ដើម្បីអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ដែលក្នុងនោះមានកម្មវិធីម្ជុលស៊ីរ៉ាំងស្អាត និងកម្មវិធីព្យាបាលជំនួស ដោយមេតាដូន។ ក្រោយទទួលបានលទ្ធផលការសិក្សាពីក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានឯកភាព និងដាក់ឱ្យអនុវត្តកម្មវិធីទាំងនេះក្នុងគោលបំណងបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍បន្តរហូតមកដល់សព្វថ្ងៃ។ បើតាមលទ្ធផលនៃការប៉ាន់ប្រមាណក្នុងឆ្នាំ២០១៧ បង្ហាញថា មានអាត្រាឆ្លង ១៥,២% ក្នុងចំណោមចាក់គ្រឿងញៀន និង ៥,៧% ក្នុងចំណោមអ្នកមិនចាក់ ចំណែកការប៉ាន់ប្រមាណក្នុងឆ្នាំ២០២៤ (មិនទាន់ជាផ្លូវការ) ១០% ក្នុងចំណោមអ្នកចាក់ និង ៦% ក្នុងចំណោមអ្នកមិនចាក់។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនត្រៀមខ្លួនរួចជាស្រេចដើម្បីបន្តគាំទ្រ និងជួយសម្របសម្រួលដល់ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ការបង្ការការឆ្លងមេរោគអេដស៍ ក្នុងចំណោមទាំងអ្នកចាក់ និងអ្នកមិនចាក់ព្រមទាំងត្រៀមផ្តល់ការសម្របសម្រួល និងកិច្ចអន្តរាគមន៍ដើម្បីឈានទៅសម្រេចគោលដៅ ដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានដាក់ចេញ និងលើកឡើងពីអត្ថប្រយោជន៍ App NoDrug និងបានសំណូមពរឱ្យមានការចូលរួមប្រើប្រាស់ទាំងអស់គ្នា។

ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិត **ឈឹម ឃិនដារ៉េត** បានបន្តថា ក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៃការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន តាមរយៈការដាក់ចេញនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដើម្បីការបញ្ចប់អេដស៍ជាការគំរាមកំហែងដល់សុខភាពសាធារណៈ ដោយបានកំណត់កម្មវត្ថុចំនួនបីគឺ៖

-ទី១ ការឆ្លងថ្មីនៃមេរោគអេដស៍តិចជាង១នាក់ ក្នុងមួយថ្ងៃ ឬក្នុងរង្វង់ជាង២០០នាក់ក្នុងមួយឆ្នាំ។

-ទី២ កាត់បន្ថយការស្លាប់ដោយសារអេដស៍តិចជាង២០០នាក់ក្នុងមួយឆ្នាំ។

-ទី៣ លុបបំបាត់ការរើសអើង និងការមាក់ងាយអ្នកផ្ទុកមេរោគអេដស៍។

សូមរំលឹកឡើងវិញពីការចូលរួមឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ចាប់តាំងពីការរកឃើញមេរោគអេដស៍ជាលើកដំបូងនៅប្រទេសកម្ពុជានាឆ្នាំ១៩៩១ ទាំងលើផ្នែកបង្ការ ការព្យាបាល និងគាំទ្រ រហូតមកដល់ឆ្នាំ២០២៣នេះ កម្ពុជាសម្រេចបាន ៨៩-៩៨-៩៨ ក្រោមចក្ខុវិស័យដឹកនាំប្រកបដោយគតិបណ្ឌិត និងយកចិត្តទុកដាក់ខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រយ៉ាងមានប្រសិទ្ធភាព រួមជាមួយការអំពាវនាវជាចលនាជាតិតែមួយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ចុងបញ្ចប់ ឯកឧត្តមបណ្ឌិតអគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នារវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមាន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់។ ការចម្លងច្រើន ប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ ធានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

សម្រាប់កិច្ចប្រជុំបន្ទាប់នឹងកំណត់យកថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៥

**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈីម យិនដារ៉េត**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទាក់ទង**
**និងចលនាប្រភពធនធាន**

**វេជ្ជ. ហួត សេរីវុធ**

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**